# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០២១

## ការពង្រឹងភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ សម្រាប់ការផ្តល់សេវាសាធារណៈបានកាន់តែល្អប្រសើរ

ថ្ងៃនេះ លោក Andreas Zurbrugg ឯកអគ្គរាជទូតរងអូស្ត្រាលី រួមជាមួយលោក Bryan Fornari នាយកផ្នែកសហប្រតិបត្តិការរបស់សហភាពអឺរ៉ុប និងលោកស្រី Maryam Salim នាយិកាធនាគារពិភពលោក មានកិត្តិយសបានចូលរួមជាមួយឯកឧត្តម ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដើម្បីបើកវគ្គបណ្តុះបណ្តាល ស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍សម្រាប់ជំនាន់ទី២នៃមន្ត្រីជាន់ខ្ពស់។

វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ មានគោលបំណងលើកកម្ពស់សមត្ថភាពរបស់មន្ត្រីជាន់ខ្ពស់ និងបង្កើតចំណងសហការណ៍ដ៏រឹងមាំ រវាងថ្នាក់ដឹកនាំរបស់កំណែទម្រង់សាធារណៈរបស់រដ្ឋាភិបាលកម្ពុជា។

ឯកអគ្គរាជទូតរង Zurbrugg បានមានប្រសាសន៍ថា "ភាពជាអ្នកដឹកនាំមិនមែនកំណត់ត្រឹមតែការគ្រប់គ្រង និងធ្វើការសម្រេចចិត្តទេ គឺរួមបញ្ចូលទាំងការបង្កើតវប្បធម៌ដ៏ល្អ ការផ្តល់នូវការលើកទឹកចិត្តសមស្រប ការជំរុញក្នុងការគ្រប់គ្រងហានិភ័យដ៏ម៉ត់ចត់ និងការលើកកម្ពស់គណនេយ្យភាព។ នៅពេលដែលថ្នាក់លើបានផ្តល់ការទុកចិត្តមកលើយើង និងបន្ទាប់ពីយើងបានផ្តល់ការទុកចិត្ត ទៅដល់ក្រុមការងារ អ្នកដឹកនាំអាចជំរុញអោយមាននវានុវត្តន៍ និងកំណត់ទិសដៅច្បាស់លាស់សម្រាប់កំណែទម្រង់សាធារណៈ។"

វគ្គបណ្តុះបណ្តាលនេះ ជាសកម្មភាពសំខាន់មួយ ក្រោមមូលនិធិពហុម្ចាស់ជំនួយសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និងការផ្តល់សេវាសាធារណៈ (MDTF)។ រដ្ឋាភិបាលអូស្ត្រាលី និងសហភាពអឺរ៉ុបបានផ្តល់ជំនួយចំនួន ២លានដុល្លារអូស្ត្រាលី និង២លានអឺរ៉ូទៅដល់ MDTF ដែលគ្រប់គ្រងដោយធនាគារពិភពលោក។ MDTF បានសហការជាមួយសាលាភូមិន្ទរដ្ឋបាល ដើម្បីបង្កើត និងគ្រប់គ្រងវគ្គបណ្តុះបណ្តាលនេះ។

មន្ត្រីជាន់ខ្ពស់ជាង ១៥០នាក់ រួមទាំងអគ្គនាយកនៃអគ្គនាយកដ្ឋាន និងរដ្ឋលេខាធិការនៃក្រសួងនីមួយៗរបស់រដ្ឋាភិបាលកម្ពុជា បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au